## Pinochet Case[1]

១. Pinochet ជាមេដឹកនាំយោធា គ្រប់គ្រងប្រទេស ឈីលី ពីឆ្នាំ ១៩៧៣ ដល់ ឆ្នាំ ១៩៩០ បន្ទាប់ពីផ្តួលរំលំយកអំណាចពីលោក Salvatore Allende។ គាត់បានចុះពីអំណាច និងក្លាយជាព្រឹទ្ធសភាមួយជីវិត (senator for life) ក្នុងឆ្នាំ ១៩៩៨ ដែលគាត់នៅមានអំណាចលើយោធា និង ក្នុងនីតិបញ្ញត្តិ និងមានអភ័យឯកសិទ្ធិ។ ក្នុងអំឡុងពេលកាន់អំណាច គាត់បានប្រើប្រាស់កណ្តាប់ដៃហិង្សា ក្នុងប្រតិបត្តិការ Operation Condor ចាប់ខ្លួន ធ្វើទារុណកម្ម លើជនកុំមុនីស្ត ដែលប្រឆាំងនឹងគាត់ ធ្វើឲ្យពួក គេរង ឈឺចាប់ និងស្លាប់ជាច្រើននាក់ ។

២. ឆ្នាំ ១៩៩៨ គាត់បានទៅកាន់ចក្រភពអង់គ្លេសដើម្បីព្យាបាលជំងឺ។ ដំណឹងនេះ បានលឺដល់ជនជាតិអេស្ប៉ាញ ដែលធ្លាប់ជាជនរងគ្រោះ ហើយបានដាក់បណ្តឹងទៅតុលាការប្រទេសអេស្ប៉ាញ ស្នើឲ្យមានសំណើសុំប្រទេសអង់គ្លេសបញ្ជូនគាត់ ទៅប្រឈមមុខនឹងការចោទប្រកាន់ពីបទ ចាប់ចំណាប់ខ្មាំង និងអំពើទារុណកម្ម នៅមុខតុលាការអេស្ប៉ាញ។ សំណើនេះ នាំឲ្យមានការពិចារណាចាប់ខ្លួនលោក Pinochet ជាបណ្តោះអាសន្ន (interim arrest warrant)។ តុលាការអង់គ្លេស បានពិចារណាសំណុំរឿង ជាបី( Pinochet 1,2 and 3)។ ទីមួយ ពាក់ព័ន្ធ ដីកាស្នើឲ្យឃាត់ខ្លួន និងបញ្ហា អភ័យឯកសិទ្ធិ របស់ Pinochet ដែលអាចរារាំងមិនឲ្យមានការឃាត់ខ្លួន។ ក្នុងសំណុំរឿងទី ១ ចៅក្រម (house of lord) ៣រូប ក្នុងចំណោម ៥រូប បានឯកភាព ឲ្យដីកាឃាត់ខ្លួន មានប្រសិទ្ធភាព។ ទោះបីជាយ៉ាងនេះក្តី សេចក្តីសម្រេចនេះ មានបញ្ហាផ្លូវច្បាប់ ដោយសារ មានការលម្អៀង (ភរិយារបស់ចៅក្រមមួយរូប ជាមន្ត្រីនៃអង្គការលើកលែងទោសអន្តរជាតិ ដែលជាភាគីទីបី ដាក់បទអន្តរាគមន៍ក្នុងសំណុំរឿងនេះ) (សំណុំរឿងទី២)។ សំណុំរឿងទី៣ មានសមាសភាពចៅក្រមចំនួន ៧ រូប។ ចៅក្រម ៦រូប បាន អះអាងថា អំពើទារុណកម្ម មិនមែនជា កិច្ចការងាររបស់រដ្ឋ (act of state) ដូចនេះ លោក Pinochet មិនអាចយកអភ័យឯកសិទ្ធិមករាំងដំណើរការបត្យាប័នបានទេ។

៣. ក្នុងសំណុំរឿងទីបីនេះ មានភាពចំរូងរាស់ ពាក់ព័ន្ធបត្យាប័ន គឺបទល្មើសអាចបត្យាប័នបាន (extraditable offence) និងគោលការណ៍ (dual criminality) ដែលនាំឲ្យកាត់បន្ថយចំនួនបទល្មើសមួយចំនួនក្នុងសំណើសម្រាប់បត្យាប័ន។ រដ្ឋាភិបាលអង់គ្លេស ទោះបីជា House of Lords បើកភ្លើងខៀវ ឲ្យបញ្ជូនលោក Pinochet ទៅប្រទេសអេស្ប៉ាញក្តី រដ្ឋាភិបាលបានប្រើឆន្ទានុសិទ្ធិមិន

[1] *R v. Bow Street Stipendiary Magistrate ex parte Pinochet Ugarte*, 38 ILM (1999) 581.

បញ្ជូន ផ្អែកតាមកត្តាមនុស្សធម៌ (សុខភាពរបស់ Pinochet) ហើយបានបញ្ជូនគាត់ទៅ ប្រទេសដើមវិញ។ នៅទីនោះ គាត់បានទទួលរងការចោទប្រកាន់នូវបទល្មើស ដោយតុលាការក្នុងស្រុកនៃប្រទេសរបស់គាត់។

**<u>ដកស្រង់ពី Robert Cryer, Pinochet Case in Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 872-875</u>.**

**<u>កំណត់សំគាល់</u>៖** ក្នុងរឿងនេះមានបញ្ហាពាក់ព័ន្ធនឹងបទល្មើសអាចធ្វើបត្យាប័នបាន ខ្ញុំសូមលើកយកមាត្រាខ្លះនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដើម្បីពិនិត្យនិងងាយស្រួលយល់ខ្លឹមសារ។

**<u>មាត្រា ៥៦៩</u>**៖ បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើផង និងតាមច្បាប់កម្ពុជាផង ទោះបីជា ៖ - អំពើដែលជាបទល្មើសស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ - ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ - ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើ គឺជាការប្រព្រឹត្តិបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា និង**<u>មាត្រា មាត្រា ៥៧១ (លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ</u>**)៖ បត្យាប័នអាចធ្វើបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់ទៅលើបុគ្គលដែលគេទាមទារនោះ មានកម្រិតអតិបរមានៃទោសពន្ធនាគារយ៉ាងតិចស្មើនឹង ២ (ពីរ) ឆ្នាំ តាមច្បាប់នៃរដ្ឋធ្វើសំណើ ។ ប៉ុន្តែបត្យាប័នក៏អាចធ្វើបានដែរ ប្រសិនបើបុគ្គលដែលគេទាមទារនោះ ត្រូវបានតុលាការនៃរដ្ឋធ្វើសំណើ ផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនឹង ៦ (ប្រាំមួយ) ខែ ហើយសេចក្តីសម្រេចផ្តន្ទាទោសនេះបានចូលជាស្ថាពររួចហើយ ទោះបីជាទោសដែលកំណត់ដោយច្បាប់មានថិរវេលាប៉ុន្មានក៏ដោយ ។